**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**លេខ៖ បព ០២/២០២៦ កបទ.សអ**

សេចក្តីប្រកាសព័ត៌មាន

# ខ្លឹមសារបទបង្ហាញជូនអង្គទូត ស្តីពីការវិវត្តចុងក្រោយនៃស្ថានការណ៍ព្រំដែនកម្ពុជា-ថៃ

នៅរសៀលថ្ងៃទី ៦ ខែមករា ឆ្នាំ២០២៦ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ធ្វើបទបង្ហាញជូនប្រធាន និងតំណាងនៃស្ថានបេសកកម្មការទូត និងអង្គការអន្តរជាតិនៅភ្នំពេញ អំពីបច្ចុប្បន្នភាពនៃការវិវត្តស្ថានការណ៍តាមបណ្តោយព្រំដែនកម្ពុជា-ថៃ។

ជាកិច្ចចាប់ផ្តើម ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានថ្លែងអំណរគុណចំពោះការបន្តចូលរួមសកម្មភាពរបស់អង្គទូត និងបានកត់សម្គាល់ថា បន្ទាប់ពីកំណើនភាពតានតឹងថ្មីៗនេះ ស្ថានការណ៍ហាក់ដូចជាកំពុងវិលមករកផ្លូវត្រូវវិញ ដូចបានឆ្លុះបញ្ចាំងដោយការសម្រេចបាននូវសមិទ្ធផលផ្នែកការទូតសំខាន់ៗ ដែលរួមមានកិច្ចប្រជុំពិសេសរបស់រដ្ឋមន្ត្រីការបរទេសអាស៊ាន នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី នាថ្ងៃទី ២២ ខែធ្នូ កិច្ចប្រជុំពិសេសលើកទី៣នៃគណៈកម្មាធិការព្រំដែនទូទៅ(GBC) រវាងកម្ពុជា-ថៃ នាថ្ងៃទី ២៧ ខែធ្នូ និងកិច្ចប្រជុំត្រីភាគីរវាងកម្ពុជា ថៃ និងចិន នៅខេត្តយូណាន ប្រទេសចិន នាថ្ងៃទី ២៩ ខែធ្នូ ឆ្នាំ២០២៥។

ឯកឧត្តម ប្រាក់ សុខុន បានគូសបញ្ជាក់អំពីលទ្ធផលវិជ្ជមាននៃសេចក្តីប្រកាសរួមនៃកិច្ចប្រជុំពិសេសលើកទី៣នៃគណៈកម្មាធិការព្រំដែនទូទៅ(GBC)រវាងកម្ពុជា-ថៃ ដែលឆ្លើយតបនឹងអាទិភាពសំខាន់ៗសំដៅកាត់បន្ថយភាពតានតឹង ការកសាងទំនុកចិត្ត ក៏ដូចជាការស្តារសន្តិភាព និងភាពប្រក្រតីឡើងវិញ ក្នុងនោះរួមមានបទឈប់បាញ់ដែលមានប្រសិទ្ធភាពចាប់ពីថ្ងៃត្រង់ថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០២៥ ការព្រមព្រៀងដើម្បីជានាឱ្យជនភៀសសឹកផ្ទៃក្នុងប្រទេសអាចវិលត្រឡប់ទៅផ្ទះសម្បែងវិញដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ដោយគ្មានការរារាំង និងការប្តេជ្ញាចិត្តឡើងវិញ ចំពោះដំណោះស្រាយជម្លោះដោយសន្តិវិធី តាមរយៈការដោះស្រាយឫសគល់នៃជម្លោះ រួមទាំងការបន្តឡើងវិញនូវការងាររបស់គណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីក៏បានស្វាគមន៍ចំពោះការដោះលែងយោធិនកម្ពុជាទាំង១៨រូប ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការកសាងទំនុកចិត្តឡើងវិញ និងបានសម្តែងនូវអំណរគុណដល់គ្រប់ភាគីទាំងអស់ដែលបានគាំទ្រ និងរួមចំណែកដល់ការវិវត្តជាវិជ្ជមានទាំងនេះ។

ទោះជាយ៉ាងណាក្តី ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានសម្តែងការព្រួយបារម្ភយ៉ាងខ្លាំងថាជនភៀសសឹកកម្ពុជារាប់សិបម៉ឺននាក់នៅតែមិនទាន់អាចវិលត្រឡប់ទៅផ្ទះសម្បែងរបស់ពួកគេ នៅតាមមូលដ្ឋានជាច្រើនក្នុងខេត្តចំនួនបួនរបស់កម្ពុជា។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានលើកអំពីការបន្តវត្តមានយោធា ព្រមទាំងសកម្មភាពទាំងឡាយដែលបានប៉ះពាល់ដល់រចនាសម្ព័ន្ធស៊ីវិល និងរំលោភត្រឡប់

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

ចូលទៅតំបន់ទាំងនេះ។ ឯកឧត្តមបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការធានាឱ្យសកម្មភាពដាក់ស្តែង ដើរស្របនឹងការប្តេជ្ញាចិត្តចំពោះបទឈប់បាញ់ និងគោលការណ៍អន្តរជាតិពាក់ព័ន្ធ ក៏ដូចជាស្មារតីកិច្ចសហប្រតិបត្តិការអាស៊ាន។

ស្តីពីបញ្ហាព្រំដែន ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានបញ្ជាក់ថា កម្ពុជា និងថៃមានព្រំដែនរួមដែលទទួលស្គាល់ជាអន្តរជាតិ កំណត់ដោយផែនទីដែលផលិតឡើងស្របតាមអនុសញ្ញាឆ្នាំ១៩០៤ និងសន្ធិសញ្ញាឆ្នាំ១៩០៧។ ឯកឧត្តមបានលើកពីវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការងារកំណត់ព្រំដែនដែលសម្រេចបានដោយគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក ជាពិសេសក្នុងពេលថ្មីៗនេះនៅទីតាំងចន្លោះបង្គោលព្រំដែនលេខ ៥២-៥៩ និង ៤២-៤៧ និងបានរំលឹកឡើងវិញនូវចំណុចទី៣នៃសេចក្តីប្រកាសរួមរបស់កិច្ចប្រជុំពិសេសលើកទី៣ នៃគណៈកម្មាធិការព្រំដែនទូទៅ (GBC) រវាងកម្ពុជា-ថៃ ដែលបញ្ជាក់យ៉ាងច្បាស់ថា រាល់ការព្រមព្រៀងទាំងអស់ក្រោមសេចក្តីប្រកាសរួមនេះ គឺមិនប៉ះពាល់ដល់ការងារវាស់វែង និងខណ្ឌសីមាព្រំដែនឡើយ។ ក្នុងន័យនេះ កម្ពុជាបានស្នើឱ្យមានការកោះប្រជុំគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោកជាបន្ទាន់ ដើម្បីពន្លឿនការងារស្របតាមស្មារតីនៃសេចក្តីប្រកាសរួម។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានគូសបញ្ជាក់ថា កម្ពុជានៅតែប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ក្នុងការធានាការរក្សាបទឈប់បាញ់បច្ចុប្បន្នឱ្យនៅខ្ជាប់ខ្ជួន។ អាទិភាពបន្ទាន់របស់កម្ពុជាគឺការអនុវត្តបទឈប់បាញ់ និងកិច្ចព្រមព្រៀងពាក់ព័ន្ធឱ្យបានពេញលេញ ដោយស្មោះត្រង់ និងប្រកបដោយសុច្ឆន្ទៈ រួមទាំងការអនុញ្ញាតឱ្យប្រជាជនស៊ីវិលភៀសសឹកបានវិលត្រឡប់ទៅទីលំនៅវិញប្រកបដោយសុវត្ថិភាព និងសេចក្តីថ្លៃថ្នូរ ការដោះស្រាយជម្លោះដោយសន្តិវិធីតាមរយៈយន្តការដែលមានស្រាប់ ការបន្តការងារវាស់វែង និងកំណត់ខណ្ឌសីមាព្រំដែនដោយគណៈកម្មការចម្រុះខណ្ឌសីមាព្រំដែនគោក កិច្ចសហប្រតិបត្តិការដាក់ស្តែងក្រោមក្របខ័ណ្ឌដែលបានព្រមព្រៀងគ្នា រួមទាំងការដោះមីនមនុស្សធម៌តាមរយៈក្រុមការងារសម្របសម្រួលរួមការដោះមីនស្របតាមស្តង់ដារនីតិវិធីប្រតិបត្តិការដែលបានព្រមព្រៀងគ្នា និងការរក្សាច្រកទំនាក់ទំនងបើកចំហរវាងអាជ្ញាធរយោធា និងក្រសួងការបរទេស។ ឯកឧត្តមបានសង្កត់ធ្ងន់បន្ថែមទៀតអំពីសារៈសំខាន់នៃការពង្រឹងតួនាទីរបស់ក្រុមអ្នកសង្កេតការណ៍អាស៊ាន ដើម្បីផ្ទៀងផ្ទាត់ និងធានាការអនុវត្តពេញលេញនៃបទឈប់បាញ់ ព្រមទាំងវិធានការចាំបាច់ផ្សេងទៀតដែលបានព្រមព្រៀងគ្នា ដើម្បីតម្លាភាព ការកសាងទំនុកចិត្ត និងការជឿទុកចិត្តគ្នា។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានសង្កត់ធ្ងន់ថា **កម្ពុជា និងថៃ គឺជាប្រទេសជិតខាង ហើយនឹងនៅតែជាប្រទេសជិតខាងរហូតតទៅមុខ** ដែលមានការទទួលខុសត្រូវរួមគ្នាដើម្បីធានាសន្តិភាព ស្ថិរភាព និងវិបុលភាពចីរកាលសម្រាប់ប្រជាជននៃប្រទេសទាំងពីរ សម្រាប់តំបន់ និងសម្រាប់គ្រួសារអាស៊ាន។ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីបានបញ្ជាក់ជាថ្មីថា កម្ពុជាជ្រើសរើសយកសន្តិភាព និងការដោះស្រាយជម្លោះដោយសន្តិវិធី និងតាមផ្លូវការទូតដើម្បីការពារអធិបតេយ្យ និងបូរណភាពទឹកដីរបស់ខ្លួន។

តំណាងក្រសួងការពារជាតិ និងលេខាធិការដ្ឋានកិច្ចការព្រំដែន ក៏បានធ្វើសេចក្តីរាយការណ៍ និងបទបង្ហាញអំពីបច្ចុប្បន្នភាពនៃស្ថានភាពព្រំដែនផងដែរ។

ថ្ងៃអង្គារ ៣រោច ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី៦ខែមករា ឆ្នាំ ២០២៦